# សិក្ខាសាលាផ្សព្វផ្សាយថ្នាក់តំបន់ ស្តីពី

## “អភិក្រមក្របដណ្តប់លើវិស័យពាណិជ្ជកម្ម, លទ្ធផលពាក់កណ្តាលគម្រោង, ការត្រួតពិនិត្យ, ការវាយតម្លៃ និងផលប៉ះពាល់ នៃកម្មវិធីពិពិធកម្មនិងពង្រីកការនាំចេញ ជំហានទី ២ (CEDEP II) ក្រោមកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម”

បាត់ដំបង, សណ្ឋាគារខេមរាបាត់ដំបង ១, ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦

**សុន្ទរកថាបើកកម្មវិធី ដោយ លោកជំទាវ តឹករ៉េត កំរង**

**រដ្ឋលេខាធិកា ក្រសួងពាណិជ្ជកម្ម និងជាមន្ត្រីបង្គោលរបស់ EIF**

- **លោក/ឯកឧត្តម** ................................................................ អភិបាលខេត្ត (រង) បាត់ដំបង
- លោក-លោកស្រី តំណាងឲ្យសភាពាណិជ្ជកម្មខេត្ត, មន្ទីរពាណិជ្ជកម្ម, មន្ទីរកសិកម្ម, រុក្ខាប្រមាញ់ និងនេសាទ, មន្ទីរឧស្សាហាកម្ម និងសិប្បកម្ម, មន្ទីរកិច្ចការនារី, មន្ទីរអភិវឌ្ឍន៍ជនបទ, មន្ទីរទេសចរណ៍, មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃខេត្តទាំងប្រាំពីររួមមាន៖ ខេត្តបាត់ដំបង, ប៉ៃលិន, បន្ទាយមានជ័យ, ឧត្តរមានជ័យ, ព្រះវិហារ, ពោធិ៍សាត់ និងកំពង់ឆ្នាំង!
- សមាជិកក្រុមស្នូល
- តំណាងអ្នកទទួលផលរបស់គម្រោង (ប្រធានសមាគមដំឡូងមីស្រុកសំពៅលូន, ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង, សមាគមដំឡូងមី ក្រុងប៉ៃលិន និង ស្រុកសាលាក្រៅ ខេត្តប៉ៃលិន និង ក្រុមហ៊ុនសិប្បកម្មទឹកត្រីង៉ូវ ហេង ខេត្តកំពត)
- លោក លោកស្រី អ្នកនាងកញ្ញា សមាជិក សមាជិកា នៃអង្គសិក្ខាសាលា ទាំងមូលជាទីមេត្រី

ជាបឋម នាងខ្ញុំមានក្តីសោមនស្សរីករាយ ដែលបានអញ្ជើញចូលរួមជាអធិបតីក្នុងកម្មវិធីសិក្ខាសាលានាពេលនេះ ជំនួសមុខឲ្យថ្នាក់ដឹកនាំនៃក្រសួងពាណិជ្ជកម្ម ខ្ញុំសូមស្វាគមន៍ និងថ្លែងអំណរគុណដល់វត្តមានរបស់ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលបានចូលរួមសិក្ខាសាលាផ្សព្វផ្សាយថ្នាក់តំបន់លើកទី ២ ក្រោមប្រធានបទស្តីពី **“អភិក្រមក្របដណ្តប់លើវិស័យពាណិជ្ជកម្ម, លទ្ធផលពាក់កណ្តាលគម្រោង, ការត្រួតពិនិត្យ, ការវាយតម្លៃ និងផលប៉ះពាល់ នៃកម្មវិធីពិពិធកម្មនិងពង្រីកការនាំចេញ ជំហានទី ២ (CEDEP II) ក្រោមកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម”**។

ឆ្លៀតឱកាសនេះ ខ្ញុំសូមជំម្រាបជូន **ឯកឧត្តម លោក លោកស្រី នាងកញ្ញា** មេត្តាជ្រាបថា៖ ក្រសួងពាណិជ្ជកម្ម ក្រោមការដឹកនាំរបស់ **ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បាននឹងកំពុងកសាងទំនុកចិត្ត និងទំនាក់ទំនងល្អជាមួយបណ្តាប្រទេសមួយចំនួននៅអាស៊ីបូព៌ា និងសហភាពអឺរ៉ុប ដើម្បីកៀងគរអ្នកវិនិយោគទុនបរទេសឱ្យចូលមកបណ្តាក់ទុន និងវិនិយោគនៅក្នុងប្រទេសកម្ពុជា ។ ជាពិសេសក្រសួងពាណិជ្ជកម្ម បាននិងកំពុងធ្វើកំណែទម្រង់ស៊ីជម្រៅរបស់ខ្លួនរួមមាន (១) កំណែទម្រង់រចនាសម្ព័ន្ធផ្ទៃក្នុង (២) អភិវឌ្ឍន៍ធនធានមនុស្ស និង (៣) កំណែទម្រង់ស្វ័យប្រវត្តិកម្ម ដូចជា ស្វ័យប្រវត្តិកម្មនៃវិញ្ញា

បណ្ណប័ត្រប្រភពដើម, ស្វ័យប្រវត្តិនៃការចុះបញ្ជីពាណិជ្ជកម្ម, និងគេហទំព័រព័ត៌មានពាណិជ្ជកម្មក្នុងចំណោមកំណែទម្រង់ផ្សេងៗទៀត។

លើសពីនេះ ក្រសួងពាណិជ្ជកម្ម បានទទួលការគាំទ្រពីដៃគូអភិវឌ្ឍន៍ ក្នុងការចងក្រងរៀបចំឯកសារ **អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម** ហៅកាត់ **Trade SWAp** នៅដើមឆ្នាំ ២០០៨ ។ យុទ្ធសាស្ត្រស្នូលនៃ Trade SWAp នេះគឺជា**យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (CTIS)** ដែលត្រូវបានធ្វើបច្ចុប្បន្នភាពចុងក្រោយបំផុតសម្រាប់រយៈពេល (២០១៤-២០១៨) និងបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការដោយ**សម្តេចនាយករដ្ឋមន្ត្រី** ក្នុងខែកុម្ភៈ ឆ្នាំ ២០១៥។ CTIS និងផែនទីបង្ហាញផ្លូវ បានអនុញ្ញាតឱ្យក្រសួងពាណិជ្ជកម្ម ចាប់ផ្តើមធ្វើកំណែទម្រង់របស់ខ្លួនរហូតមកដល់ពេលបច្ចុប្បន្ននេះ។ ឧទាហរណ៍ ការគាំទ្រនៃកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម (EIF) គឺបានផ្តល់មូលនិធិសម្រាប់ការកសាងសមត្ថភាពស្ថាប័ន និងដើរតួនាទីយ៉ាងសំខាន់ ក្នុងការកសាងសមត្ថភាពមន្ត្រីនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងពាណិជ្ជកម្ម ក៏ដូចជាមន្ត្រីតាមបណ្តាក្រសួងពាក់ព័ន្ធមួយចំនួនផ្សេងទៀត ជាពិសេស មន្ត្រីទំនាក់ទំនង និងសមាជិកក្រុមការងារស្នូលនៃកម្មវិធី EIF ។

**ឯកឧត្តម លោក លោកស្រី នាងកញ្ញា** យើងទាំងអស់គ្នាដឹងហើយថា កំណើន សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានស្ថិរភាពខ្លាំងណាស់សម្រាប់រយៈពេល ១០ ឆ្នាំនេះ បើទោះបីជានៅក្នុងប្រទេសជិតខាងមានភាពមិនប្រាកដប្រជា និងអស្ថេរភាពក៏ដោយ។ ការអភិវឌ្ឍន៍ នៃរបៀបវារៈកំណែទម្រង់ដ៏ជាក់លាក់ជាមួយនឹងគោលដៅផ្សារភ្ជាប់ទៅនឹងកំណែទម្រង់អាទិភាព និងក្របខ័ណ្ឌត្រួតពិនិត្យដ៏រឹងមាំបានជួយបង្កើនប្រសិទ្ធភាពនៃការប្រតិបត្តិនៃសេដ្ឋកិច្ចរបស់រដ្ឋាភិបាល។

ទោះបីមានកំណើនសេដ្ឋកិច្ចល្អក្តី កម្ពុជានៅមានបញ្ហាប្រឈមនៅឡើយដូចជា ៖ (១) ការប្រកួតប្រជែងនាំចេញជាមួយប្រទេសជិតខាងនៅក្នុងតំបន់អាស៊ីបូព៌ា និងទីផ្សារអឺរ៉ុប និង (២) បរិយាកាសវិនិយោគផលិតភាព និងវិស័យសេវាកម្មនៅមានកម្រិតនៅឡើយ។ ដូច្នោះ ដើម្បីចូលរួមរក្សាកំណើនសេដ្ឋកិច្ច និងកាត់បន្ថយបញ្ហាប្រឈមនានាគឺទាមទាឲ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមមាន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន រដ្ឋាភិបាល ជាពិសេស ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងវិស័យឯកជន ដែលមានវត្តមានក្នុងថ្ងៃនេះ គឺមានតួនាទីសំខាន់ខ្លាំងណាស់ព្រោះថា ខេត្តមួយចំនួនបាននឹងកំពុងផលិត ផលិតផល និងសេវាកម្មដែលមានសក្តានុពលមួយចំនួនសម្រាប់ការនាំចេញទៅកាន់ទីផ្សាក្នុងតំបន់ និងអន្តរជាតិ។ ការចូលរួមរបស់ពីថ្នាក់ខេត្ត និងវិស័យឯកជនគឺជាយន្តការប្រកួតប្រជែងមួយប្រកបដោយសក្តានុពល ដើម្បីធ្វើឱ្យប្រសើរឡើងនូវជំនាញបច្ចេកទេសសម្ភារៈបរិក្ខារ និងចំណេះដឹងដែលទាក់ទងទៅនឹងវិស័យពាណិជ្ជកម្ម។ មន្ត្រីគ្រប់លំដាប់ថ្នាក់គួរតែមានចំណេះដឹងថ្មីៗ និងយល់ដឹងពីនិន្នាការ និងការវិវឌ្ឍន៍របស់ប្រទេសជាតិ ជាពិសេស ចំពោះការផ្តួចផ្តើម និងការដឹកនាំអនុវត្តន៍ការងាររបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងពាក់ព័ន្ធដ៏ទៃទៀត។

កម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម ជំហ៊ាន ២ (EIF Tier 2) ឬកម្មវិធីពិពិធកម្ម និងពង្រីកការនាំចេញកម្ពុជា ជំហ៊ាន ទី១ និងទី២ (CEDEP I and CEDEP II) ត្រូវបានបង្កើតឡើងដើម្បីជាការឆ្លើយតបទៅនឹងបំណងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការជំរុញសេដ្ឋកិច្ច និងជាការតាមដានពិនិត្យឡើងវិញនូវគោលនយោបាយពាណិជ្ជកម្មរបស់កម្ពុជាក្រោមអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។ ឥឡូវនេះរចនាសម្ព័ន្ធ CEDEP ត្រូវបានអនុវត្តទៅលើវិស័យផ្សេងគ្នា និងបានកំនត់នៅក្នុង CTIS 2014-2018 ដែលជាអ្នកទទួលផលក្នុងការនាំចេញដ៏សំខាន់ ។

គម្រោង CEDEP I មានសមាសភាគដូចជា សូត្រប្រណិត (បានបញ្ចប់កាលពីខែ មីនា ២០១៦), អង្ករ (បានបញ្ចប់ត្រឹមខែមិថុនា ២០១៦), និងមុខងារវាយតម្លៃ នឹងបញ្ចប់ការងាររបស់ខ្លួននៅពាក់កណ្តាលខែតុលា ឆ្នាំ ២០១៦ ខាងមុខនេះ ។ តួនាទីរបស់ក្រសួងពាណិជ្ជកម្ម គឺដើម្បីជានាឱ្យបាននូវការអនុវត្តគម្រោងទៅតាមផែនការដែលបានអនុម័ត និងឲ្យស្របទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលកម្ពុជា ដើម្បីជាការត្រួតពិនិត្យ និងវាយតម្លៃពីការរីកចំរើនឆ្ពោះទៅរកលទ្ធផលរំពឹងទុក ។

ដោយឡែក កម្មវិធីពិពិធកម្ម និងពង្រីកការនាំចេញកម្ពុជា ជំហ៊ានទី២ (ហៅថា CEDEP II) ត្រូវបានសម្ពោធឲ្យអនុវត្តកាលតាំងពីដើមឆ្នាំ២០១៤ ដែលផ្តោតសំខាន់លើ ការនាំចេញ**ផលិតផលជំឡូងមី** (UNDP), **ផលិតផលជលផលសមុទ្រ** (UNIDO), ការបង្កើត**សាលាបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើម្ហូបអាហារ** (Shift 360) និង**មុខងារវាយតម្លៃ** (DICO/MoC)។ សូមបញ្ជាក់ថា ប្រទេសកម្ពុជាបានក្លាយជាអ្នកផលិតដំឡូងមីធំមួយ។ ទោះជាយ៉ាងណា ភាគច្រើនបំផុតនៃការផលិតរបស់យើងត្រូវបាននាំចេញក្រៅផ្លូវការ ដូចជា មើមដំឡូងមិនទាន់កែច្នៃ ហើយយើងនៅមិនទាន់ចាប់យកតម្លៃបន្ថែមពីវិស័យនេះនៅឡើយ តាមរយៈការកែច្នៃផលិតផលពាក់កណ្តាល សម្រេច និងដំណើរកែច្នៃតាមបែបជឿនលឿន។ យើងមានឱកាសជាច្រើន ប៉ុន្តែសមត្ថភាពផលិត និងបរិយាកាសគោលនយោបាយចាំបាច់ត្រូវបង្កើតឡើងដើម្បីគាំទ្រវិស័យដំឡូងមី។ ដូចគ្នា **ផលិតផលជលផលសមុទ្រ** ក៏ត្រូវបាន នាំចេញក្រៅផ្លូវការផងដែរទៅបណ្តា ប្រទេសជិតខាង។ ចំណែក **សមាសភាគសាលាបណ្តុះបណ្តាលធ្វើម្ហូបកម្ពុជា** (ACAC)វិញ ទើបតែទទួលបានការអនុម័តពីលេខាធិការដ្ឋាន EIF កាលពីថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១៥ និងបានចាប់ផ្តើមអនុវត្តជាផ្លូវការនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៥ ក្នុងភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជន (PPP) ដោយមានការគាំទ្រពីកម្មវិធី EIF និង SIDA ដែលគម្រោងនេះអាចជួយដោះស្រាយបញ្ហាកង្វះជំនាញសំខាន់ៗនៅក្នុងវិស័យបដិសណ្ឋារកិច្ច។ គម្រោងនេះ បាននិងកំពុងអនុវត្តដោយអង្គការ Shift 360 និងបានសហការគ្នាជាមួយនិងរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងទេសចរណ៍ និងវិស័យឯកជន (សមាគមសណ្ឋាគារ, ភោជនីយដ្ឋាន, និងចុងភៅ)។ ដូច្នេះ ការចូលរួមរបស់រដ្ឋាភិបាល និងវិស័យឯកជនក្នុងការងារតាមដានវាយតម្លៃ និងផ្សព្វផ្សាយក្នុងគម្រោងទាំងនេះ គឺនឹងជួយពង្រឹងភាពជាដៃគូរ ជាពិសេសចូលរួមចំណែកក្នុងការជួយជម្រុញវិស័យនាំចេញផលិតផលក្នុងប្រទេសកម្ពុជា កាន់តែរីកចំរើនខ្លាំងឡើង។

ជាចុងបញ្ចប់នេះ ខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោក លោកស្រី នាងកញ្ញាទាំងអស់គ្នា ដែលបានចំណាយពេលវេលាចូលរួម ដើម្បីចែករំលែកទស្សនៈផ្ទាល់ខ្លួននិងចំណេះដឹងដល់កម្មវិធីសាលាក្នុងថ្ងៃនេះ។ ខ្ញុំសូមជូនពរ ឯកឧត្តម លោក លោកស្រី មានសុខភាពល្អ និងទទួលជោគជ័យគ្រប់ភារៈកិច្ច។ ខ្ញុំ សូមប្រកាសបើកកម្មវិធីសិក្ខាសាលា និងសូមឲ្យសិក្ខាសាលារយៈពេលមួយថ្ងៃនេះ ប្រព្រឹត្តិទៅប្រកបដោយផ្លែផ្កាល្អ ។

***សូមអរគុណ !***

***